ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ: ០៥៤/២៥ គ.ជ.ប.ជ

# របាយការណ៍
## ស្តីពី
## ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ
## ប្រចាំខែកុម្ភៈ និងទិសដៅខែមីនា ឆ្នាំ២០២៥

### I. ស្ថានភាពទូទៅ

ពិភពលោក កំពុងតែប្រឈមដោះស្រាយវិបត្តិសេដ្ឋកិច្ចជាសាកល ផលប៉ះពាល់នៃគ្រោះធម្មជាតិ ដែលកើតឡើងដោយបម្រែបម្រួលអាកាសធាតុ និងសង្គ្រាមប្រដាប់អាវុធដ៏រ៉ាំរ៉ៃ ដែលជំរុញឱ្យមនុស្សរាប់រយលាននាក់បង្ខំចិត្តចាកចេញពីផ្ទះសម្បែង ឬទីតាំងដែលខ្លួនរស់នៅ ហើយធ្វើទេសន្តរប្រវេសន៍ដោយគ្មានការត្រៀមទុក ដែលក្លាយជាចលនាលំហូរពលករដែលគ្មានឯកសារ ខ្វះការគ្រប់គ្រង ដែលប្រឈមយ៉ាងខ្លាំងទៅនឹងកង្វះសុវត្ថិភាព អំពើរំលោភបំពាន និងការកេងប្រវ័ញ្ចជាច្រើនរូបភាព។

ការផ្សព្វផ្សាយយ៉ាងទូលំទូលាយរបស់បណ្តាញសារព័ត៌មាននានា ទាំងពិត ទាំងមិនពិត អំពីបទល្មើសជួញដូរមនុស្សនៅកម្ពុជា ព្រមទាំងការចោទប្រកាន់ពីបណ្តាប្រទេស ដែលមានពលរដ្ឋមកប្រព្រឹត្តបទល្មើស ឬមករងគ្រោះនៅកម្ពុជា បានធ្វើឱ្យមានការភ័ន្តច្រឡំ និងវាយតម្លៃជាអវិជ្ជមានលើស្ថានភាពសន្តិសុខនៅកម្ពុជា ដែលនាំឱ្យមានភាពរាំងស្ទះដល់ដំណើរការនៃចរន្តសេដ្ឋកិច្ចជាតិ និងប៉ះពាល់ដល់ជីវភាពរបស់ប្រជាពលរដ្ឋ។

ការផ្សព្វផ្សាយអំពីឱកាសការងារ និងការជ្រើសរើសពលករទៅធ្វើការនៅក្រៅប្រទេស ទាំងតាមប្រព័ន្ធផ្លូវការ ទាំងតាមបណ្តាញសង្គម និងមួយចំនួនធំជាការអូសទាញរបស់បណ្តាញជនល្មើស បានក្លាយជាកត្តាជំរុញ និងទាក់ទាញប្រជាពលរដ្ឋក្នុងតំបន់ និងពីបណ្តាប្រទេសនានាក្នុងពិភពលោក ក៏ដូចជាប្រជាជនកម្ពុជាដែលពេញវ័យការងារឱ្យចាប់អារម្មណ៍ និងសម្រេចចិត្តយ៉ាងឆាប់រហ័ស និងផុលផុស ក្នុងការធ្វើចំណាកស្រុក ឬធ្វើទេសន្តរប្រវេសន៍ទៅរកការងារ ដែលមានបៀវត្សរ៍ខ្ពស់ ជាពិសេសពាក់ព័ន្ធនឹងសកម្មភាពឆបោក។ ចំនួនដ៏ច្រើនលើសលប់នៃប្រជាជនពេញវ័យការងារបានធ្វើចំណាកស្រុក មានរហូតដល់ជាងមួយលាននាក់ បាននិងកំពុងនៅធ្វើការងាររហូតដល់ប្រមាណ ១.៦លាននាក់ នៅក្រៅប្រទេស ដែលស្មើនឹង ជិត២០ភាគរយ នៃប្រជាពលរដ្ឋវ័យ ពី១៥ឆ្នាំ ទៅ ៦០ឆ្នាំ និងអត្រាដ៏ខ្ពស់ នៃការបោះបង់ការសិក្សាក្នុងកម្រិតមធ្យមសិក្សា បានប៉ះពាល់ទៅនឹងកង្វះធនធានពលកម្ម សម្រាប់ទទួលយកការងារដែលត្រូវបានបង្កើតឡើងក្នុងស្រុក តាមរយៈការវិនិយោគលើវិស័យឧស្សាហកម្ម និងសហគ្រាសធំៗ ដែលរាជរដ្ឋាភិបាលបាននិងកំពុងទាក់ទាញការចាប់អារម្មណ៍ពីអន្តរជាតិ។

រាជរដ្ឋាភិបាលក្នុងនីតិកាលទី៧ បានចាត់ទុកការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាអាទិភាពមួយក្នុងចំណោមអាទិភាពដទៃទៀត រួមទាំងផលប៉ះពាល់នៃគ្រឿងញៀន គ្រឿងស្រវឹង គ្រោះថ្នាក់ចរាចរណ៍ និងបានដាក់ចេញនូវយុទ្ធសាស្ត្រឆ្លើយតបកាន់តែមានប្រសិទ្ធភាព ដោយខិតខំជំរុញសកម្មភាពឥតឈប់ឈរ ដើម្បីការពារសុវត្ថិភាព និងសន្តិសុខមនុស្ស ក៏ដូចជាសន្តិសុខជាតិទាំងមូល ដើម្បីទ្រទ្រង់ដំណើរការអភិវឌ្ឍន៍គ្រប់វិស័យ។

នៅក្នុងខែកុម្ភៈនេះ គ្រប់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងរាជធានី-ខេត្ត ក្នុងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅគ្រប់កម្រិត ដោយមានការចូលរួមគាំទ្រ និងសហការពីអង្គការដៃគូជាតិ និងអន្តរជាតិពាក់ព័ន្ធ បានធ្វើសកម្មភាពប្រតិបត្តិការយ៉ាងសកម្ម តាមយុទ្ធសាស្ត្រទាំងបួន នៃផែនការយុទ្ធសាស្ត្រជាតិ ដោយប្រឈមនឹងស្ថានភាពប្រែប្រួលឥតឈប់ឈរនៃបទល្មើស។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងកិច្ចសហប្រតិបត្តិការ (គ្មាន)

### ខ. ការបង្ការ ទប់ស្កាត់

#### ខ.១. ការលើកកម្ពស់ការយល់ដឹងតាមរយៈការអប់រំផ្សព្វផ្សាយដោយផ្ទាល់

ក្រុមការងារបង្ការ ទប់ស្កាត់ នៃ គ.ជ.ប.ជ ដឹកនាំដោយក្រសួងអប់រំ យុវជន និងកីឡា ដែលមានស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សហការជាមួយអង្គការដៃគូ បានធ្វើការផ្សព្វផ្សាយតាមរយៈការប្រារព្ធកម្មវិធីយុទ្ធនាការគាំទ្រទិវាសុវត្ថិភាពអ៊ីនធឺណិតឆ្នាំ២០២៥ ការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព" វេទិកាសាធារណៈ និងការបញ្ជ្រាបការផ្សព្វផ្សាយតាមកម្មវិធីផ្សេងៗ សរុបចំនួន **១៥.៧៥២**លើក មានអ្នកចូលរួមសរុបចំនួន **៧៧២.៦១៤**នាក់ ក្នុងនោះស្ត្រី ៤២៨.០២០នាក់ (ធៀបនឹងខែមករា មានចំនួន ៧៩០.៦២២នាក់) គឺមានការថយចុះចំនួន ១៨.០០៨នាក់ ស្មើនឹង២,២៧% ដូចមានក្នុងតារាងខាងក្រោម៖

*(សម្គាល់៖ ចំនួននេះគិតត្រឹមអ្នកចូលរួមផ្ទាល់ ដោយមិនគិតអ្នកដែលបានទទួលព័ត៌មានតាមបណ្តាញសង្គម ការអប់រំបែបសាសនា ឬការផ្សព្វផ្សាយតាមប្រព័ន្ធអេឡិកត្រូនិកផ្សេងទៀតទេ)*

*តារាងទិន្នន័យសរុបការផ្សព្វផ្សាយដោយផ្ទាល់*

| ល.រ | សកម្មភាពផ្សព្វផ្សាយ | ចំនួនដង/លើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ០១ | យុទ្ធនាការគាំទ្រទិវាសុវត្ថិភាពអ៊ីនធឺណិតឆ្នាំ២០២៥ | ០២ | ១.៨០៥ | ៣៥៥ |
| ០២ | ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព និងវេទិកាសាធារណៈ | ១៥.១១០ | ៧២៨.២៣៤ | ៤០៨.១០៦ |
| ០៣ | កម្មវិធីផ្សេងៗ | ៦៤០ | ៤២.៥៧៥ | ១៩.៥៥៩ |
| សរុប | | ១៥.៧៥២លើក | ៧៧២.៦១៤នាក់ | ៤២៨.០២០នាក់ |

❖ **យុទ្ធនាការគាំទ្រទិវាសុវត្ថិភាពអ៊ីនធឺណិតឆ្នាំ២០២៥**

▪ ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងអង្គការ APLE រៀបចំកម្មវិធីផ្សព្វផ្សាយមុនយុទ្ធនាការគាំទ្រទិវាសុវត្ថិភាពអ៊ីនធឺណិតឆ្នាំ២០២៥ ក្រោមអធិបតីភាព លោកជំទាវបណ្ឌិត **សឿ សុជាតា** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា មានលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ចូលរួមចំនួន **៧០៥**នាក់ (ស្រី ៣៥៥នាក់) នៅសាលាប៊ែលធីអន្តរជាតិ។

▪ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយកិច្ចសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងប្រៃសណីយ៍ ព្រមទាំងមានការចូលរួមសហការឧបត្ថម្ភ ពីអង្គការ APLE, OneChild, Terre des Hommes, Childhood, ម្លប់តាប៉ាង និងក្រុមហ៊ុនស្មាតអាស៊ីតា បានប្រារព្ធកម្មវិធីអបអរសាទរយុទ្ធនាការគាំទ្រទិវាសុវត្ថិភាពអ៊ីនធឺណិតឆ្នាំ២០២៥ ក្រោមប្រធានបទ "កុមារឆ្លាតវៃយល់ដឹងពីសុវត្ថិភាព និងចេះការពារខ្លួនតាមអនឡាញ" ក្រោមអធិបតីភាព លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ. តំណាងឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គលេខាធិការ អគ្គលេខាធិការរង អគ្គនាយក អគ្គនាយករង ប្រធាន អនុប្រធាននាយកដ្ឋាន តំណាងអង្គការដៃគូជាតិ អន្តរជាតិ តំណាងក្រុមហ៊ុនឯកជន លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស សរុបប្រមាណ ១.១០០នាក់ នៅវិទ្យាស្ថានជាតិអប់រំ។

## ❖ ការផ្សព្វផ្សាយតាមរយៈវេទិកាសាធារណៈ និងភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព

| ល.រ | ក្រសួង ស្ថាប័ន | ផ្សព្វផ្សាយ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | រាជធានី-ខេត្ត | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| រាជធានី-ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | ១៣៤ | ៤៤.៣៥០ | ២២.៣៥០ | ១៨៥ | ១.១៥៦ | ៩១២ |
| ២ | កណ្ដាល | ៦៤៨ | ៥០.២៣៨ | ៣២.៧៧០ | | | |
| ៣ | បាត់ដំបង | ៩៦៨ | ៤៩.៧០២ | ២៧.៣០២ | ៦៨៤ | ២២.១៩៦ | ១២.៤៩៨ |
| ៤ | ពោធិ៍សាត់ | | | | | | |
| ៥ | សៀមរាប | ៨១៥ | ៦៩.៧៤៤ | ៤០.៨៥៤ | ៥៦៣ | ២១.១៩៧ | ១៣.៤៣៩ |
| ៦ | កំពង់ឆ្នាំង | ៧៩៤ | ៣៣.៤៦៦ | ១៩.១៧៣ | ៣៧៦ | ១៣.០៥៩ | ៧.០៦០ |
| ៧ | កំពង់ចាម | ១.៧៦២ | ៩៩.៣៨៧ | ៥១.៧១៩ | ១ | ៦០ | ២៤ |
| ៨ | ព្រះសីហនុ | ១៤៦ | ៤.១៣៣ | ២.២២១ | ៨៣ | ២.៣៣៣ | ១.៣២៥ |
| ៩ | ព្រះវិហារ | ៣ | ១.៤៨៨ | ៧៩៣ | | | |
| ១០ | ស្វាយរៀង | ៣៧៩ | ២០.៩៧២ | ១១.២២៨ | ៤៧២ | ១៩.៨៨៧ | ១០.២២៨ |
| ១១ | ប៉ៃលិន | ៥ | ២៣៣ | ១៣៥ | ៨១ | ២.១៦៩ | ៩៩៥ |
| ១២ | កោះកុង | ៦៥៣ | ១២.៧៧៩ | ៦.៤៨៤ | ២៦២ | ៤.២៨៨ | ២.២២១ |
| ១៣ | កំពត | | | | | | |
| ១៤ | កំពង់ធំ | ៤៧២ | ២៩.០៦៩ | ១៦.៦៨៤ | ២០៨ | ៧.១១៦ | ៣.៩៥១ |
| ១៥ | តាកែវ | | | | | | |
| ១៦ | ក្រចេះ | ៨៥ | ១.០៨០ | ៦៨៥ | | | |
| ១៧ | កែប | ៥៥ | ៧.៥៤០ | ៣.៩៤៤ | ១១៧ | ៤.៣៣៧ | ២.៣៤៦ |
| ១៨ | កំពង់ស្ពឺ | ៣០៥ | ២១.៣៣៤ | ១១.៤៣៩ | ១៥ | ២.៥០៥ | ១.៣២៩ |
| ១៩ | ស្ទឹងត្រែង | | | | | | |
| ២០ | រតនគិរី | ៤៩៤ | ២១.០៤៥ | ១០.០៩៧ | ១៥៣ | ៧.១៦៨ | ៣.៤៤៣ |
| ២១ | ព្រៃវែង | ១.១៨៧ | ៧៨.៨៥០ | ៤៣.៧៦៥ | ៧៨៥ | ២៧.៧២០ | ១៥.០៧៤ |
| ២២ | ត្បូងឃ្មុំ | ៥០ | ៣៩៤១ | ១.៩៦២ | ១៤៨ | ៤.១៥០ | ១.៨៥០ |
| ២៣ | បន្ទាយមានជ័យ | ១.១០០ | ២០.៧១៤ | ១១.៩២៧ | ៣២៥ | ៧.៥៥៧ | ៤.៨៨៧ |
| ២៤ | ឧត្តរមានជ័យ | ១៤៨ | ៧.៤៦៧ | ៤.២៦២ | ១១ | ៤៣៣ | ២៤៦ |
| ២៥ | មណ្ឌលគិរី | ៤១១ | ១២.៣០១ | ៥.៩៦៥ | ២៧ | ១.០៧០ | ៥១៩ |
| សរុប រាជធានី-ខេត្ត | | ១០.៦១៤លើក | ៥៧៩.៨៣៣នាក់ | ៣២៥.៧៥៩នាក់ | ៤.៤៩៦លើក | ១៤៨.៤០១នាក់ | ៨២.៣៤៧នាក់ |
| សរុបរួម | | ១៥.១១០លើក | | ៧២៨.២៣៤នាក់ | | ៤០៨.១០៦នាក់ | |

## ❖ ការបញ្ជ្រាបការយល់ដឹងតាមរយៈកម្មវិធីផ្សេងៗ

| ល.រ | ក្រសួង ស្ថាប័ន រាជធានី-ខេត្ត | ចំនួនលើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃ គ.ជ.ប.ជ | ០៨ | ១.១៦២ | ៦៣២ |
| ២ | ខេត្តកណ្ដាល | ២៤២ | ៨.៣២៣ | ៤.១៧៧ |
| ៣ | ខេត្តប៉ៃលិន | ០២ | ១២៨ | ៦៥ |
| ៤ | ខេត្តសៀមរាប | ៤៧ | ៤.៦៣៤ | ២.៤៧២ |
| ៥ | ខេត្តកំពង់ឆ្នាំង | ៦៦ | ១.៤០១ | ៧៣៤ |

| | | | | |
|---|---|---|---|---|
| ៦ | ខេត្តកំពង់ចាម | ១២ | ៥៩១ | ៣៤៩ |
| ៧ | ខេត្តព្រះវិហារ | ០៤ | ៩០៩ | ២៤៦ |
| ៨ | ខេត្តត្បូងឃ្មុំ | ០៨ | ១.២០៩ | ៦៤០ |
| ៩ | ខេត្តឧត្តរមានជ័យ | ១៧៩ | ១២.៩៧៦ | ៤.១១៥ |
| ១០ | ខេត្តក្រចេះ | ០៤ | ៨០៥ | ៤២៧ |
| ១១ | ខេត្តបន្ទាយមានជ័យ | ៤០ | ៤.២៣៥ | ២.៣៤៤ |
| ១២ | ខេត្តកំពង់ធំ | ១៤ | ១.៧៨៣ | ៨៤១ |
| ១៣ | ខេត្តកំពង់ស្ពឺ | ១៤ | ៤.៤១៩ | ២.៥១៧ |
| ១៤ | អង្គការ Friend Insertional (សៀមរាប) | ១៥៣ | ១.៧៣៨ | ៨៥០ |
| ១៥ | អង្គការសាម៉ារីតាន់គីស(បាត់ដំបង) | ០៨ | ២.៤៤៤ | ១.៣៦៧ |
| សរុប | | ៦៤០លើក | ៤២.៥៧៥នាក់ | ១៩.៥៥៩នាក់ |

## ខ.២. ការលើកកម្ពស់ការយល់ដឹងតាមរយៈការអប់រំផ្សព្វផ្សាយដោយមិនផ្ទាល់

❖ **ការផលិត និងចែកផ្សាយសម្ភារផ្ដល់ព័ត៌មាន និងអប់រំ** (IEC = Information Education Communication Materials)

| ល.រ | ក្រសួង ស្ថាប័ន រាជធានី-ខេត្ត | សកម្មភាព និងឧបករណ៍ផ្សព្វផ្សាយ | ចំនួនលើក | ចំនួនឧបករណ៍ | ចំនួនអ្នកទទួលបាន | ចំនួនស្ត្រី |
|---|---|---|---|---|---|---|
| ១ | សៀមរាប | -ខិតប័ណ្ណផ្សព្វផ្សាយ | | ២៦.២៧៩សន្លឹក | ៣.៦០០នាក់ | ១.៦០០នាក់ |
| ២ | បាត់ដំបង | -ខិតប័ណ្ណផ្សព្វផ្សាយ | | ៣.០៤២សន្លឹក | | |
| ៣ | បន្ទាយមានជ័យ | -ខិត្តប័ណ្ណផ្សព្វផ្សាយ | | | ១.១៤៨នាក់ | ៥៣៨នាក់ |
| ៤ | ព្រះវិហារ | -ខិត្តប័ណ្ណផ្សព្វផ្សាយ | ១២ | ១២សន្លឹក | ៤៥៧នាក់ | ១២០នាក់ |
| ៥ | ឧត្តរមានជ័យ | -ខិត្តប័ណ្ណផ្សព្វផ្សាយ | | ១.៥៧០សន្លឹក | | |
| សរុប | | | ១២លើក | ៣០.៩០៣សន្លឹក | ៥.២០៥នាក់ | ២.២៥៨នាក់ |

❖ **ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក**

| ល.រ | ក្រសួង ស្ថាប័ន រាជធានី-ខេត្ត | បណ្ដាញផ្សព្វផ្សាយ | ចំនួនលើក/ដង/ស្ពត | ចំនួនអ្នកទស្សនា/ស្ដាប់/អាន/Views |
|---|---|---|---|---|
| ១ | ក្រុមជំនួយកិច្ចការបង្ការទប់ស្កាត់ នៃគ.ជ.ប.ជ | -ជំរុញក្រុមហ៊ុនទូរស័ព្ទ ធ្វើការផ្សព្វផ្សាយសារអប់រំដល់ប្រជាពលរដ្ឋ តាមរយៈទូរស័ព្ទចល័ត ដើម្បីចូលរួមកម្មវិធីយុទ្ធនាការគាំទ្រទិវាសុវត្ថិភាពអ៊ីនធឺណិតឆ្នាំ២០២៥ ខ្លឹមសារ "កុមារឆ្លាតវៃយល់ដឹងពីសុវត្ថិភាព និងចេះការពារខ្លួនតាមអនឡាញ"។ | ០១ | |
| ២ | ខេត្តសៀមរាប | -វិទ្យុជាតិ | ១៩៩ | |
| ៣ | ខេត្តប៉ៃលិន | -វិទ្យុជាតិ | ៤៩៦ | |
| ៤ | ខេត្តព្រៃវែង | -វិទ្យុជាតិ | ៥០ | |
| ៥ | ខេត្តកំពង់ចាម | -វិទ្យុជាតិ | ០៣ | |
| ៦ | ខេត្តត្បូងឃ្មុំ | -វិទ្យុជាតិ | ៣២ | |
| ៧ | ខេត្តបន្ទាយមានជ័យ | -វិទ្យុជាតិ | ០៨ | |
| សរុប | | | ៧៧៩លើក | |

❖ ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ នៅតាមស្ថានីយវិទ្យុ និងទូរទស្សន៍

| ល.រ | ក្រសួង ស្ថាប័ន រាជធានី-ខេត្ត | វិទ្យុ ទូរទស្សន៍ និងផ្សេងៗ | ចំនួនលើក |
|---|---|---|---|
| ១ | គណៈកម្មាធិការជាតិ គ.ជ.ប.ជ | លោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ<br>-ផ្តល់សម្ភាសន៍ជាមួយសារព័ត៌មាន Fresh News ស្តីពី"ការជួញដូរមនុស្ស និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមអនឡាញ" ដើម្បីផ្សព្វផ្សាយ។<br>-ចូលរួមកម្មវិធី "Matter Podcast" ក្រោមប្រធានបទ "ស្ត្រីក្នុងភាពជាអ្នកដឹកនាំនៃដំណើរការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស" ដើម្បីអបអរសាទរ និងចូលរួមចែករំលែកបទពិសោធន៍ ក្នុងទិវានារីអន្តរជាតិខួបលើកទី១១៤។ | ០១<br><br><br>០១ |

## ខ.៣. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

### ខ.៣.១. ការបង្ការ ទប់ស្កាត់ការជួញដូរមនុស្ស តាមរយៈរូបភាពរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តច្បាប់) បានសម្ភាសន៍ជនបរទេស ដែលមកដាក់ពាក្យសុំចុះបញ្ជីរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ តាមផ្លូវច្បាប់ សរុបចំនួន **២០៣**នាក់ (ស្រី **១៥**នាក់) មាន **១៤**សញ្ជាតិ និងបានវាយតម្លៃបញ្ជូនឯកសារឱ្យក្រុមការងារប្រកចេញ-ចូលតែមួយ ក្រសួងមហាផ្ទៃចំនួន **៥៧៤**នាក់ (ស្រី ៣៥នាក់) ។

| បរិយាយ | ចំនួន | សញ្ជាតិ |
|---|---|---|
| ស្រីបរទេសជាមួយបុរសខ្មែរ | ១៥នាក់ | ចិន ៩៨នាក់(ស្រី០១នាក់) កូរ៉េខាងត្បូង ៤៨នាក់(ស្រី០៦នាក់) អាម៉េរិក ៣៦នាក់ (ស្រី០៣នាក់) អូស្ត្រាលី ០៥នាក់(ស្រី០២នាក់) បារាំង ០៣នាក់ ជប៉ុន០៣នាក់(ស្រី០១នាក់) ម៉ាឡេស៊ី ០២នាក់ កាណាដា ០២នាក់ អង់គ្លេស ០១នាក់(ស្រី) ស្វីស ០១នាក់ សិង្ហបុរី ០១នាក់ ហុងគ្រី ០១នាក់ ឆែក០១នាក់ ហូឡង់០១នាក់(ស្រី)។ |
| បុរសបរទេសជាមួយស្រីខ្មែរ | ១៨៨នាក់ | |
| សរុប | ២០៣ នាក់ | ១៤ សញ្ជាតិ |

### ខ.៣.២. ការគ្រប់គ្រងស្ថិតិចំណាកស្រុក ចំណូលស្រុក ពលរដ្ឋខ្មែរ និងជនបរទេស

❖ ការគ្រប់គ្រងស្ថិតិបច្ចុប្បន្នភាពចំណាកស្រុក ចំណូលស្រុក ពលរដ្ឋខ្មែរ

▪ **អគ្គស្នងការដ្ឋាននគរបាលជាតិ** បានតាមដាន និងធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកទៅក្រៅប្រទេស និងត្រឡប់មកវិញ តាមរយៈការប្រមូលទិន្នន័យពីបណ្តាស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ទូទាំងប្រទេស ដូចមានក្នុងតារាងខាងក្រោម៖

| ប្រចាំខែ | ទិន្នន័យពលរដ្ឋខ្មែរចំណាកស្រុកទៅក្រៅប្រទេស | | | |
|---|---|---|---|---|
| | សរុប | ស្រី | អនីតិជន | |
| | | | សរុប | ស្រី |
| កុម្ភៈ | ១៤១.៥០៨នាក់ | ៦២.៦២៦នាក់ | ៤.១៣១នាក់ | ១.៣៣៧នាក់ |
| ប្រចាំខែ | ទិន្នន័យពលរដ្ឋខ្មែរដែលវិលត្រឡប់ពីក្រៅប្រទេស | | | |
| | សរុប | ស្រី | អនីតិជន | |
| | | | សរុប | ស្រី |
| កុម្ភៈ | ១៤.៦២៩នាក់ | ៦.០០៨នាក់ | ១៨៦នាក់ | ៧៥នាក់ |

❖ ការទទួលពលរដ្ឋខ្មែរចំណាកស្រុកដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់

- ស្ថិតិពលរដ្ឋខ្មែរដែលត្រូវអាជ្ញាធរបរទេសបញ្ជូនត្រឡប់តាមច្រកទ្វារព្រំដែន

| ល.រ | រាជធានី-ខេត្ត | ចំនួនរួម | ស្រី | អនីតិជន | ស្រី |
|---|---|---|---|---|---|
| ១ | បន្ទាយមានជ័យ | ៣៥៨ | ១១៦ | | |
| ២ | បាត់ដំបង | ០៧ | | | |
| ៣ | កោះកុង | ១៩ | ១០ | ១៣ | ០៦ |
| ៤ | ស្វាយរៀង | ១៩ | ០២ | | |
| | សរុប | ៤០៣នាក់ | ១២៨នាក់ | ១៣នាក់ | ០៦នាក់ |

- ការទទួលពលករនៅតាមមណ្ឌលទទួលពលករ

▪ មជ្ឈមណ្ឌលសំចត និងស្តារនីតិសម្បទាជនរងគ្រោះប៉ោយប៉ែត បានទទួលជនរងគ្រោះ និងបុគ្គលសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្ស សរុបចំនួន ០៨នាក់ (ប្រុស ០២នាក់ អនីតិជនប្រុស ០៣នាក់ អនីតិជនស្រី ០៣នាក់)។ ក្នុងនោះមាន៖

- ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ធ្វើមាតុភូមិនិវត្តន៍ពីប្រទេសថៃចំនួន ០៥នាក់ (អនីតិជនប្រុស០៣នាក់ អនីតិជនស្រី០២នាក់) ជាករណីកេងប្រវ័ញ្ចកម្លាំងពលកម្ម។
- បុគ្គលសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្សក្នុងប្រទេសចំនួន ០៣នាក់ (ប្រុស០២នាក់ អនីតិជនស្រី០១នាក់)។ អង្គការ IOM ចំនួន ០២នាក់(ប្រុស) និងអង្គការក្តីស្រឡាញ់គ្មានព្រំដែន អនីតិជនស្រី០១នាក់។

➢ *បានបញ្ជូនទៅទទួលសេវាសហគមន៍ មានអនីតិជនប្រុស ០២នាក់។ និងស្នាក់នៅក្នុងមជ្ឈមណ្ឌលស្តារនីតិសម្បទាចំនួន ០៦នាក់ (ប្រុស ០២នាក់ អនីតិជនប្រុស ០១នាក់ អនីតិជនស្រី ០៣នាក់)។*

- បានទទួលពលករចំណាកស្រុកដែលបញ្ជូនត្រឡប់មកពីប្រទេសថៃនិរទេស សរុបចំនួន ៤៣១នាក់ (ប្រុស ២៤៨នាក់ ស្រី ១៣៨នាក់ អនីតិជនប្រុស ១៨នាក់ អនីតិជនស្រី ២៧នាក់)។

▪ មណ្ឌលទទួលពលករកំរៀង៖ បានទទួលពលករ សរុបចំនួន ២៨នាក់ (ស្រី ០៦នាក់) អនីតិជន ០២នាក់។ និងបានកំណត់អត្តសញ្ញាណបឋមបុគ្គលសង្ស័យថារងគ្រោះចំនួន ២៦នាក់ (ស្រី ០៤នាក់)។

## ខ.៤. កិច្ចការពារកុមារពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ

❖ **ការធ្វើអធិការកិច្ច**

| ក្រសួង ស្ថាប័ន រាជធានី-ខេត្ត | ចំនួនគោលដៅ/គ្រឹះស្ថាន/សហគ្រាស | លទ្ធផល |
|---|---|---|
| មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តព្រះវិហារ | ១១សហគ្រាស | - បានចុះអធិការកិច្ចលើសហគ្រាសវិស័យ កសិ-ឧស្សាហកម្ម។<br>- ពិនិត្យពីបែបបទ នៃដំណើរការការងាររបស់សហគ្រាស។<br>- ពិនិត្យលើច្បាប់ស្តីពីការងារ ច្បាប់ស្តីពីលក្ខខ័ណ្ឌ អនាម័យ សុវត្ថិភាព និងសុខភាពការងារ។<br>- បានដាក់កំហិតលើសហគ្រាស។ |
| មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល | ៣៥សិប្បកម្ម | - ចុះធ្វើអធិការកិច្ចការងារត្រួតពិនិត្យ លើការបំពេញបែបបទស្តីពីសហគ្រាស និងលក្ខខ័ណ្ឌការងារសិប្បកម្មផលិតឥដ្ឋ។ |

| | | |
|---|---|---|
| | | - មានកុមារអាយុក្រោម១២ឆ្នាំ ចំនួន១៩៦នាក់ (ស្រី៩៤នាក់) និងកុមារអាយុ១៥ឆ្នាំឡើង ចំនួន២៨នាក់(ស្រី១២នាក់) ដែលរស់នៅជាមួយឪពុក ម្តាយ ក្នុងសិប្បកម្ម។<br>- ក្រុមការងារពុំបានរកឃើញមានការប្រើប្រាស់ និងការជួញដូរកម្លាំងពលកម្មទេ។<br>- បានធ្វើកិច្ចសន្យាហាមឃាត់ ការប្រើប្រាស់កម្លាំងពលកម្មលើកុមារ មានចំនួន១០៥គ្រួសារ និងធ្វើលិខិតធានាជាមួយម្ចាស់សិប្បកម្ម ចំនួន៣៥សិប្បកម្ម។ |
| មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប | ២៧សិប្បកម្ម | - ចុះអធិការកិច្ចការងារតាមសិប្បកម្មផលិតឥដ្ឋ ក្នុងស្រុកវ៉ារិន ស្រុកសូទ្រនិគម ស្រុកជីក្រែង ស្រុកបន្ទាយស្រី ស្រុកអង្គរជុំ ស្រុកអង្គរធំ និងស្រុកក្រឡាញ់ (បើកដំណើរការ ចំនួន២៦សិប្បកម្ម និងបិទដំណើរការចំនួន០១សិប្បកម្ម) ក្នុងនោះមានសិប្បកម្មផលិតឥដ្ឋជាលក្ខណៈគ្រួសារ ចំនួន០៦សិប្បកម្ម។<br>- បានដាក់កំហិតនូវចំណុច ដែលគ្រឹះស្ថានអនុវត្តមិនទាន់បានត្រឹមត្រូវ តាមច្បាប់ស្តីពីការងារ។<br>- បានធ្វើលិខិតធានាអះអាង ជាមួយនិយោជកពីការហាមឃាត់ការប្រើប្រាស់កម្មករវ័យក្មេង។<br>- បានជំរុញឱ្យម្ចាស់សិប្បកម្ម ចុះឈ្មោះសហគ្រាស គ្រឹះស្ថានចូលក្នុងប្រព័ន្ធ LACMS។<br>- បានណែនាំពីការចុះឈ្មោះចូលជាសមាជិក ប.ស.ស និងអត្ថប្រយោជន៍របស់ ប.ស.ស។ |
| មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តប៉ៃលិន | ០៣សិប្បកម្ម | - បានចុះធ្វើអធិការកិច្ច ស្តីពីពលកម្មកុមារ នៅសិប្បកម្មឡឥដ្ឋ មានកម្មករនិយោជិតសរុប ៧៦នាក់ (ស្រី ៣០នាក់)។<br>- ក្រុមការងារអធិការកិច្ច បានធ្វើកិច្ចសន្យារវាងម្ចាស់សិប្បកម្ម និងកម្មករនិយោជិតជាអាណាព្យាបាលកុមារចំនួន ១៥គ្រួសារ កុមារអាយុក្រោម១៥ឆ្នាំក្នុងបន្ទុកចំនួន ២៥នាក់ ស្រី ០៩នាក់ ដើម្បីទប់ស្កាត់ ការប្រើប្រាស់កម្លាំងពលកម្មកុមារក្នុងទម្រង់ធ្ងន់ធ្ងរ និងការពារសុវត្ថិភាពកុមារក្នុងខ្សែសង្វាក់ផលិតកម្ម។ |

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### គ.១. ការងារអនុវត្តច្បាប់

ក្រុមការងារអនុវត្តច្បាប់ នៃ គ.ជ.ប.ជ ដឹកនាំដោយអគ្គស្នងការដ្ឋាននគរបាលជាតិ

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះទទួលបានពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត។

❖ ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត នៃ អគ្គស្នងការដ្ឋាននគរបាលជាតិ ព្រមទាំងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបចំនួន ១៥ករណី (ប្រៀបធៀបខែមករា ចំនួន ១១ករណី កើនឡើង ០៤ករណី) ស្មើនឹង ៣៦,៣៦% ៖

- ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្ត ចំនួន ១៩នាក់ (ស្រី ០៣នាក់) ជនជាតិចិន ០២នាក់។
- សង្គ្រោះជនរងគ្រោះចំនួន ៣៩នាក់ មានអាយុក្រោម១៥ឆ្នាំ ១១នាក់ អាយុ១៥-១៧ឆ្នាំ ១៨នាក់ និង អាយុ១៨ឆ្នាំឡើង ១០នាក់ (បញ្ជូនទៅមន្ទីរសង្គមកិច្ច ២៤នាក់ គ្រួសារ ១៥នាក់)។ ក្នុងនោះចែកជា៖

<u>ករណីអំពើជួញដូរមនុស្ស</u>

បង្ក្រាបបាន ០៣/០៣ករណី ឃាត់ខ្លួនជនសង្ស័យ ០៣នាក់ (ចិន ០១នាក់)។ សង្គ្រោះជនរងគ្រោះ ០៤នាក់ មានអាយុ១៥-១៧ឆ្នាំ ០១នាក់ និងអាយុ១៨ឆ្នាំឡើង ០៣នាក់ (បញ្ជូនទៅគ្រួសារ ០៤នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនសង្ស័យ | ជនបរទេស | ជនរងគ្រោះ |
|---|---|---|---|---|
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ០២ | ០២ | ចិន១ | ០៣ |
| -ការទិញពេស្យាចារកុមារ | ០១ | ០១ | | ០១ |
| សរុប | ០៣ ករណី | ០៣ នាក់ | ០១ នាក់ | ០៤ នាក់ |

<u>ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ</u>

បង្ក្រាបបាន ១២/០៨ករណី (កើនឡើង ០២ករណី) ឃាត់ខ្លួនជនសង្ស័យ ១៦នាក់ (ស្រី ០៣នាក់) ជនជាតិចិន០១នាក់។ សង្គ្រោះជនរងគ្រោះ ៣៥នាក់ មានអាយុក្រោម១៥ឆ្នាំ ១១នាក់ អាយុ១៥-១៧ឆ្នាំ ១៧នាក់ និងអាយុ១៨ឆ្នាំឡើង ០៧នាក់ (បញ្ជូនទៅមន្ទីរសង្គមកិច្ច ២៤នាក់ គ្រួសារ ១១នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនសង្ស័យ | ជនបរទេស | ជនរងគ្រោះ |
|---|---|---|---|---|
| -ស្ថានទម្ងន់ទោស(ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង) | ០១ | ០១ | ចិន១ | ០១ |
| -សញ្ញារកម្មទាក់ទងនឹងពេស្យាចារកុមារ | ០២ | ០៥ | | ២៤ |
| -រូបភាព និងសម្ភារៈអាសអាភាស | ០១ | ០១ | | ០១ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៨ | ០៩ | | ០៩ |
| សរុប | ១២ ករណី | ១៦ នាក់ | ០១ នាក់ | ៣៥ នាក់ |

## ឃ. កិច្ចការពារជនរងគ្រោះ

### ឃ.១. ការទទួលជនរងគ្រោះទាំងក្នុងប្រទេស និងពីក្រៅប្រទេស

ក្រុមការងារការពារជនរងគ្រោះ នៃ គ.ជ.ប.ជ ដឹកនាំដោយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (សហការជាមួយ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ មន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយ អង្គការដៃគូ) តាមរយៈនាយកដ្ឋានគាំពារជនរងគ្រោះ នៃអគ្គនាយកដ្ឋានសេវាសង្គមកិច្ច បានទទួលជនរងគ្រោះ និងបុគ្គលសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្ស ទាំងក្នុងប្រទេស និងពីក្រៅប្រទេស សរុបចំនួន ១៣នាក់ (ស្រី០៨នាក់ អនីតិជនប្រុស ០១នាក់ អនីតិជនស្រី ០៤នាក់) ក្នុងនោះមាន៖

- ជនរងគ្រោះ និងបុគ្គលសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្ស មកពីប្រទេសចិនចំនួន ១១នាក់(ស្រី ០៦នាក់ អនីតិជនប្រុស ០១នាក់ អនីតិជនស្រី ០៤នាក់) ជាករណីអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ ចំនួន១០នាក់ (ស្រី ០៦នាក់ អនីតិជនស្រី ០៤នាក់) និងងាយរងគ្រោះជាអនីតិជនប្រុស ០១នាក់។

- ជនរងគ្រោះដោយអំពើជួញដូរមនុស្សក្នុងប្រទេស ជាជនជាតិខ្មែរចំនួន ០២នាក់(ស្រី) ជាករណីអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ។

**ឃ.២. ការស្តារនីតិសម្បទា**

ជនរងគ្រោះ និងបុគ្គសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្ស បានបញ្ជូនទៅស្តារនីតិសម្បទា នៅមជ្ឈមណ្ឌល របស់អង្គការដៃគូ សរុបចំនួន ១៣នាក់ (ស្រី ០៨នាក់ អនីតិជនប្រុស ០១នាក់ អនីតិជនស្រី ០៤នាក់) ក្នុងនោះមានៈ អង្គការការីតាសកម្ពុជា ០២នាក់(ស្រី) អង្គការរតនៈអន្តរជាតិ ០៦នាក់ (ស្រី ០២នាក់ អនីតិជនស្រី ០៤នាក់) និងអង្គការមូលនិធិហាការអន្តរជាតិ ០៥នាក់ (ស្រី ០៤នាក់ អនីតិជនប្រុស ០១នាក់)។

## III. ការលើកកម្ពស់សមត្ថភាព និងការដឹកនាំសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

ក.១. ការបណ្តុះបណ្តាល(គ្មាន)

ក.២. សិក្ខាសាលា

▪ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានសហការនិងគ្រាំទ្រជាមួយអង្គការរតនៈអន្តរជាតិ រៀបចំសិក្ខាសាលាប្រកាសដាក់ឱ្យប្រើប្រាស់ ស្តីពីនីតិវិធីប្រតិបត្តិនៃដំណើរការមាតុភូមិនិវត្តន៍ជនរងគ្រោះ និងបុគ្គលសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន ០១លើក ដោយមានសិក្ខាកាមចូលរួមសរុបចំនួន ១៥២នាក់ (ស្រី ៦៦នាក់)។

▪ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានសហការជាមួយ អង្គការ UNICEF រៀបចំសិក្ខាសាសា ស្តីពីការប្រមូលទិន្នន័យថ្នាក់ជាតិ អំពីកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ ចំនួន ០១លើក ដោយមានសិក្ខាកាមចូលរួមសរុបចំនួន ៨៩នាក់ (ស្រី ៣៨នាក់)។

### ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

ខ.១. កិច្ចប្រជុំ

❖ ការរៀបចំកិច្ចប្រជុំក្នុងប្រទេស

▪ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានរៀបចំកិច្ចប្រជុំ ចំនួន ០៣លើក អ្នកចូលរួមចំនួន ៧៩នាក់ (ស្រី ២០នាក់)៖

- កិច្ចប្រជុំអន្តរក្រសួង ស្ថាប័ន កម្រិតបច្ចេកទេស ដើម្បីត្រៀមសម្រាប់កិច្ចប្រជុំពិភាក្សា និងពិនិត្យរបាយការណ៍ ស្តីពីស្ថានភាពការជួញដូរមនុស្ស (TIP Report) របស់សហរដ្ឋអាម៉េរិក ជាមួយក្រុមការងារបច្ចេកទេស នៃស្ថានទូតអាម៉េរិក ចំនួន ០១លើក អ្នកចូលរួមចំនួន ២៦នាក់ (ស្រី ០៧នាក់) នៅទីស្តីការក្រសួងមហាផ្ទៃ។

- កិច្ចប្រជុំពិភាក្សារវាង គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាមួយតំណាងក្រសួងការបរទេសអាម៉េរិក ទទួលបន្ទុករបាយការណ៍ការងារសិទ្ធិមនុស្ស និងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន ០១លើក អ្នកចូលរួមចំនួន ៣៦នាក់ (ស្រី ០៩នាក់) នៅទីស្តីការក្រសួងមហាផ្ទៃ។

- កិច្ចប្រជុំផ្ទៃក្នុង ដើម្បីពិភាក្សា និងពិនិត្យពិភាក្សាលើរបាយការណ៍ជាតិ ឆ្នាំ២០២៤ និងលើកទិសដៅឆ្នាំ២០២៥ របស់ គ.ជ.ប.ជ ចំនួន ០១លើក អ្នកចូលរួមចំនួន ១៧នាក់ (ស្រី ០៤នាក់។

❖ ការចូលរួមកិច្ចប្រជុំក្រៅប្រទេស

▪ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ អមដំណើរដោយ អគ្គលេខាធិការរងចំនួន ០២រូប គឺ លោកជំទាវ ឧត្តមសេនីយ៍ទោ **វ៉ន សិរីលក្ខិណា** និងឯកឧត្តម ឧត្តមសេនីយ៍ទោ **តែ សុថារេត** បានអញ្ជើញទៅចូលរួមកិច្ចប្រជុំ នៅប្រទេសថៃចំនួន ០២លើក៖

- កិច្ចប្រជុំលើកទី២ នៃការពិនិត្យឡើងវិញការអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្រប "Second Asia-Pacific Regional Review of Implementation of the Global Compact for Safe, Orderly and Regular Migration" ដែលមានប្រតិភូតំណាងបណ្តាប្រទេសជាសមាជិកអង្គការសហប្រជាជាតិ ចំនួន ១៣៩នាក់ និងអង្គការដៃគូពាក់ព័ន្ធចំនួន ១៤៨នាក់ ដែលរៀបចំដោយ UN-ESCAP។

- កិច្ចប្រជុំ "កិច្ចសន្ទនាលម្អិតលើកទី៣ របស់ការិយាល័យគាំទ្រប្រចាំតំបន់នៃដំណើរការបាលី(Third RSO Constructive Dialogue)" មានប្រតិភូតំណាងបណ្តាប្រទេសចំនួន ២៧នាក់ អង្គការ ស្ថាប័នពាក់ព័ន្ធចំនួន ១៦នាក់ និងអ្នកចូលរួមសរុប ៩២នាក់។

▪ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ អមដំណើរដោយ ឯកឧត្តម ឧត្តមសេនីយ៍ឯក **លី តុងហ៊ុយ** អគ្គលេខាធិការរង បានអញ្ជើញទៅចូលរួមកិច្ចប្រជុំ លើសេចក្តីព្រាងអនុស្សរណៈនៃការយោគយល់ ស្តីពី "ការពង្រឹងកិច្ចសហប្រតិបត្តិការ កិច្ចការពារកុមារដែលរងផលប៉ះពាល់ដោយការធ្វើទេសន្តរប្រវេសន៍" រវាងប្រទេសថៃ និងប្រទេសកម្ពុជា ដែលមានសមាសភាពចូលរួម សរុបចំនួន ៣៩នាក់ (ស្រី ២០នាក់) នៅប្រទេសថៃ។

**ខ.២. ជំនួបពិភាក្សាការងារ**

▪ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ

- បានទទួលជំនួបជាមួយតំណាងស្ថានទូតអាម៉េរិក ពិភាក្សាអំពីការបញ្ជូនរបាយការណ៍ឆ្លើយតបទៅក្រសួងការបរទេស សហរដ្ឋអាម៉េរិក។

- បានពិភាក្សាការងារជាមួយអង្គការ IJM ស្តីពីការងារប្រយុទ្ធប្រឆាំងបទល្មើសជួញដូរពលកម្មឆ្លងដែន ដើម្បីតម្រង់ទិសគម្រោង។

• **ខេត្តសៀមរាប៖** លេខាធិការដ្ឋាន គ.ខ.ប.ជ បានទទួលជួបពិភាក្សាការងារជាមួយអង្គការ ARM ស្តីពីការស្វែងយល់អំពីការស្នាក់នៅ ការថែទាំ និងតម្រូវការចាំបាច់នានា ដល់ជនរងគ្រោះក្នុងមណ្ឌលសំចត។

## គ. ការងារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ ៣៤លើក មានអ្នកចូលរួមសរុប ៥៥០នាក់(ស្រី ២៤៧នាក់) ក្នុងនោះមាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន ១៦លើក និងលេខាធិការដ្ឋានរាជធានី ខេត្ត ចំនួន ១៨លើក។ (ឧបសម្ព័ន្ធ១)

# IV. ការសន្និដ្ឋានវាយតម្លៃ

## ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។

- យើងមានច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួង ស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

## ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការផ្ញើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឱ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

## គ. សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្ដល់របាយការណ៍ឱ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែរបស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឱ្យលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ផ្ដល់របាយការណ៍ឱ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។
- បើកវគ្គបណ្ដុះបណ្ដាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឱ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្ដីសម្រេច ស្ដីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

### ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឱ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋាន គតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅខែមីនា ឆ្នាំ ២០២៥

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួមគឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាព ជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី...) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្ដុះបណ្ដាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្ដាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឱ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឱ្យបានត្រឹមត្រូវ។

៨. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

៩. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល។

១០. ជំរុញសាងសង់ជម្រកបណ្ដោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្ដល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្ដោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្ដាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬនៅតាមបណ្ដាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃព្រហស្បតិ៍ ១៤ រោច ខែជេស្ឋ ឆ្នាំ រោង ឆស័ក ព.ស ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមិ.ហ ឆ្នាំ២០២៥

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ-ប៊ុនអេង**

**ចម្លងជូន**

-ខុទ្ទកាល័យ សម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ ឯកឧត្ដមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្ដីរាយការណ៍"**

-ឯកឧត្ដម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន
-សមាជិកក្រុមការងារគ.ជ.ប.ជ
-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**"ដើម្បីជូនជ្រាប"**

-ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ៣៤លើក) មនុស្សចំនួន ៥៥០នាក់ (ស្រី ២៤៧នាក់)

| ស្ថាប័ន សម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | ▪ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួម<br>-ជាអធិបតី ក្នុងពិធីបិទសិក្ខាសាលា ស្តីពីការប្រមូលទិន្នន័យថ្នាក់ជាតិអំពីកុមារ ដែលរងផលប៉ះពាល់ដោយទេសន្តប្រវេសន៍។<br>-សន្និបាតត្រួតពិនិត្យលទ្ធផលការងារឆ្នាំ២០២៤ និងលើកទិសដៅការងារឆ្នាំ២០២៥ របស់ក្រសួងមហាផ្ទៃ និងបូកសរុបចលនាប្រឡងប្រណាំងអនុវត្តគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព ឆ្នាំ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។<br>-សន្និបាតបូកសរុបសកម្មភាព និងលទ្ធផលការងារចុះមូលដ្ឋានប្រចាំឆ្នាំ២០២៤ និងលើកទិសដៅអនុវត្តបន្តឆ្នាំ២០២៥ របស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។<br>-កិច្ចប្រជុំ ស្តីពីការពង្រឹងរចនាសម្ព័ន្ធ និងរបៀបរបបការងារគណៈកម្មការសាខាសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ក្រសួងមហាផ្ទៃ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ លោកជំទាវ កែ សួនសុភី ប្រធានកិត្តិយសគណៈកម្មការសាខាសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ក្រសួងមហាផ្ទៃ។<br>-កម្មវិធីយុទ្ធនាការគាំទ្រទិវាសុវត្ថិភាពអ៊ីនធឺណិតឆ្នាំ២០២៥ "កុមារឆ្លាតវៃយល់ដឹងពីសុវត្ថិភាព និងចេះការពារខ្លួនតាមអនឡាញ" របស់ក្រសួងអប់រំ យុវជន និងកីឡា។<br>▪ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួម<br>-ធ្វើបទបង្ហាញ ស្តីពីព្រឹត្តិការណ៍ និងគោលការណ៍សំខាន់ៗ ដោយសង្ខេបប្រចាំត្រីមាសទី៤ ឆ្នាំ២០២៤ របស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទីស្តីការក្រសួងមហាផ្ទៃ។<br>-ជួបសំណេះសំណាល ជាមួយមន្ត្រីនគរបាលថ្មី ដែលទើបប្រកាសតាំងស៊ុប របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅសាលប្រជុំ គ.ជ.ប.ជ។<br>-ដឹកនាំកិច្ចប្រជុំផ្ទៃក្នុង ដើម្បីត្រួតពិនិត្យផែនការសកម្មភាពឆ្នាំ២០២៥ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>-ដឹកនាំសម្របសម្រួលសកម្មភាពប្រជុំត្រួតពិនិត្យបញ្ចប់ និងកែសម្រួលខ្លឹមសារក្នុងឯកសារពាក់ព័ន្ធសិក្ខាសាលាថ្នាក់ជាតិ របស់អង្គការ UNICEF។<br>-កម្មវិធីយុទ្ធនាការគាំទ្រទិវាសុវត្ថិភាពអ៊ីនធឺណិតឆ្នាំ២០២៥ "កុមារឆ្លាតវៃយល់ដឹងពីសុវត្ថិភាព និងចេះការពារខ្លួនតាមអនឡាញ" របស់ក្រសួងអប់រំ យុវជន និងកីឡា។<br>-សន្និបាតត្រួតពិនិត្យលទ្ធផលការងារឆ្នាំ២០២៤ និងលើកទិសដៅការងារឆ្នាំ២០២៥ របស់ក្រសួងមហាផ្ទៃ និងបូកសរុបចលនាប្រឡងប្រណាំងអនុវត្តគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព ឆ្នាំ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។<br>-កិច្ចប្រជុំដើម្បីពិនិត្យលើសេចក្តីព្រាងអនុស្សរណៈនៃការយោគយល់ ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការ កិច្ចការពារកុមារដែលរងផលប៉ះពាល់ដោយការធ្វើទេសន្តប្រវេសន៍ រវាងប្រទេសថៃ និងប្រទេសកម្ពុជា នៅសណ្ឋាគារសោន់អេនម៉ូន រីវើសាយ។ |

| | |
|---|---|
| | -កិច្ចប្រជុំតាមប្រព័ន្ធវីដេអូ ស្តីពីវិធីសាស្ត្រដោះស្រាយបញ្ហាៈ សមតុល្យរវាងឱកាស និងហានិភ័យសម្រាប់កិច្ចការពារកុមារតាមប្រព័ន្ធអនឡាញ រៀបចំដោយអង្គការឆាលហ្វាន់កម្ពុជា-អូស្ត្រាលី។<br>▪ **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**<br>-លិខិតរបស់ គ.ជ.ប.ជៈ លិខិតចេញ (១៩ច្បាប់) លិខិតចូល (១៣ច្បាប់)<br>-លិខិតរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជៈ លិខិតចេញ(១៦ច្បាប់)លិខិតចូល(១៩ច្បាប់)<br>▪ **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់**<br>-ប្រជុំត្រួតពិនិត្យវឌ្ឍនភាពការងារ របស់ក្រុមការងាររៀបចំសិក្ខាសាលាថ្នាក់ជាតិ ស្តីពីផលប៉ះពាល់ទៅលើកុមារដែលធ្វើចំណាកស្រុក និងកុមារដែលឪពុកម្តាយធ្វើចំណាកស្រុក។<br>-ប្រជុំត្រៀមរៀបចំសិក្ខាសាលាថ្នាក់ជាតិ ស្តីពីការប្រមូលទិន្នន័យកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍។<br>-បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ពិនិត្យគោលការណ៍ណែនាំ រៀបចំផែនការសកម្មភាពថ្នាក់ក្រោមជាតិ ស្តីពីការគាំពារ និងអភិវឌ្ឍកុមារតូច នៅខេត្តសៀមរាប។<br>▪ **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ**<br>-បានចូលរួមសិក្ខាសាលាថ្នាក់តំបន់អាស៊ីអាគ្នេយ៍ ស្តីពីលទ្ធភាពទទួលបានសំណាងសម្រាប់ពលករចំណាកស្រុកទៅប្រទេសជប៉ុន នៅសណ្ឋាគារកាំបូឌីយ៉ា។ |
| លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ១៨លើក អ្នកចូលរួមសរុបចំនួន ៤៩៣នាក់ (ស្រី ២២៦នាក់) | |
| **ខេត្តសៀមរាប** | -លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំប្រចាំខែកុម្ភៈ ចំនួន០១លើក អ្នកចូលរួមចំនួន៥៦នាក់ ស្រី៣៤នាក់។<br>-ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ស្រុក បានរៀបចំកិច្ចប្រជុំ ចំនួន១១លើក អ្នកចូលរួមចំនួន២៩៨នាក់ ស្រី១២៤នាក់។ |
| **ខេត្តកណ្តាល** | -លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៤ និងលើកទិសដៅការងារអនុវត្តបន្តឆ្នាំ២០២៥ ចំនួន០១លើក អ្នកចូលរួមចំនួន១០៥នាក់ ស្រី៥២នាក់។<br>-ក្រុមការងារស្រុក បានរៀបចំកិច្ចប្រជុំប្រចាំខែកុម្ភៈ ចំនួន០១លើក អ្នកចូលរួមចំនួន១៩នាក់ ស្រី១១នាក់។ |
| **ខេត្តព្រះវិហារ** | -លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំប្រចាំកុម្ភៈ ចំនួន០១លើក អ្នកចូលរួមចំនន្ទួន១៥នាក់ ស្រី ០៥នាក់។ |
| **ខេត្តស្វាយរៀង** | -បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០២៤ និងលើកទិសដៅអនុវត្តបន្តឆ្នាំ២០២៥ ចំនួន០១លើក អ្នកចូលរួមចំនួន៥៧នាក់ ស្រី២១នាក់។ |
| **ខេត្តបន្ទាយមានជ័យ** | -លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំៈ<br>○ កិច្ចប្រជុំពិនិត្យរបាយការណ៍១២ខែ ឆ្នាំ២០២៤ ដើម្បីត្រៀមរៀបចំកិច្ចប្រជុំរបាយការណ៍ឆ្នាំ២០២៤ និងលើកទិសដៅអនុវត្តបន្តឆ្នាំ២០២៥ ចំនួន០១លើក។<br>○ កិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០២៤ និងលើកទិសដៅអនុវត្តបន្តឆ្នាំ២០២៥ ចំនួន០១លើក។ |